**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ ៣៩៨ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្តីពី
## ការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់



ផ្ទះលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh. CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៤៣០ ២២៥ ទូរសារ : ៨៥៥-២៣-៤៣០ ៧៩៩
Phone : 855-23-430 225 / Fax : 855-23-430 799

- បានឃើញអនុក្រឹត្យលេខ ១៨០ អនក្រ.បក ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៤ ស្ដីពីការបង្កើតអគ្គនាយកដ្ឋានលំនៅឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៧៣ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៦ ស្ដីពីការបង្កើតអគ្គាធិការដ្ឋានចំណុះក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៩៧ ស្ដីពីលិខិតអនុញ្ញាតសាងសង់
- បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលមាត្រា ៣០, មាត្រា ៣៤, មាត្រា ៣៨, មាត្រា ៥០, មាត្រា ៦៦, មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្ដីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន
- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ. បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្ដីពីបទបញ្ញត្តិទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលតារាងពន្ធតែមប្រិ៍សារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្ដីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្ដីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- យោងតាមគោលការណ៍ឯកភាពរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ៣ ខែមករា ឆ្នាំ២០១៩ លើលិខិតលេខ ១២០៣១ សហវ.អទច ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៨ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីសំណើសុំគោលការណ៍អនុញ្ញាត ដើម្បីលើកលែងការបង់កម្រៃសេវាសាធារណៈ គ្រប់ដំណាក់កាលនៃការចុះបញ្ជីដីតាំងពីដើមរហូតដល់ចប់ ចំពោះការចុះបញ្ជីលើដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ និងគរុភណ្ឌជាដីរបស់វត្ត លើកលែងតែដីដែលជាទ្រព្យសម្បត្តិរបស់សហគ្រាសសាធារណៈត្រូវបង់កម្រៃសេវាសាធារណៈជាធម្មតា
- យោងតាមការចាំបាច់របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ .-**

អនុញ្ញាតឱ្យក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ អនុវត្តការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ដើម្បីជាគុណប្រយោជន៍ដល់ថវិកាជាតិ។

**ប្រការ២ .-**

សេវាសាធារណៈដែលផ្ដល់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវបានរៀបចំជាកម្រងសេវាសាធារណៈ ដែលមានរាយលម្អិតអំពីប្រភេទសេវា តម្លៃសេវា រយៈពេលអតិបរមានៃការផ្ដល់សេវា និងសុពលភាពទៅតាមប្រភេទសេវាសាធារណៈនីមួយៗ ដូចមានចែងក្នុងឧបសម្ព័ន្ធ ភ្ជាប់នឹងប្រកាសអន្តរក្រសួងនេះ។

**ប្រការ៣ .-**

ចំពោះការចុះបញ្ជីដីលើកដំបូងលើ ដីសាធារណៈរបស់រដ្ឋ ដីឯកជនរបស់រដ្ឋ ដីគ្រឹះស្ថានសាធារណៈរដ្ឋបាល ព្រមទាំងគុរុភណ្ឌជាដីរបស់វត្ត ត្រូវបានលើកលែងការយកកម្រៃសេវាសាធារណៈ ប៉ុន្តែដីដែលជាទ្រព្យសម្បត្តិរបស់សហគ្រាសសាធារណៈ ត្រូវបង់កម្រៃសេវាសាធារណៈជាធម្មតា។ ការលើកលែងការយកកម្រៃសេវាសាធារណៈនេះមានអានុភាពប្រតិសកម្ម ប៉ុន្តែក្នុងករណីដែលកម្រៃសេវាសាធារណៈពាក់ព័ន្ធទាំងនេះ ត្រូវបានប្រមូលរួចហើយ មិនត្រូវបង្វិលសងវិញទេ។

ដើម្បីជំរុញការចុះបញ្ជីដីរដ្ឋឱ្យបានឆាប់រហ័ស អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋ ត្រូវរៀបចំសំណើសុំចុះបញ្ជីដីដែលមានលក្ខណៈដាច់ដោយដុំ ដោយឡែកចំពោះដីដែលស្ថិតនៅក្នុងដំណាក់កាលចុះបញ្ជីដីដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបន្តនីតិវិធីរហូតដល់ចប់ជាស្ថាពរ។

**ប្រការ៤ .-**

ប្រភេទអគារដែលជាកម្មវត្ថុសម្រាប់ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ រួមមាន÷

១- អគារលំនៅឋានដែលមានកម្ពស់ខ្ពស់ (លើសពី ១២ ជាន់ គិតទាំងជាន់ផ្ទាល់ដី)

២- អគារពាណិជ្ជកម្ម

៣- អគារពហុមុខងារ

៤- អគារបម្រើសេវាកម្មទេសចរណ៍

៥- អគារសណ្ឋាគារ។

**ប្រការ៥ .-**

នីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់លិខិតអនុញ្ញាតសាងសង់លើសកម្រិតសន្ទស្សន៍ប្រើប្រាស់ដីអតិបរមាផ្លូវការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**ប្រការ៦ .-**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវផ្សព្វផ្សាយជាសាធារណៈ ជាពិសេសនៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវបិទផ្សាយប្រកាសអន្តរក្រសួង និងកម្រងសេវាសាធារណៈដែលរួមមានឧបសម្ព័ន្ធនៃប្រកាសអន្តរក្រសួងនេះ ព្រមទាំងនីតិវិធី និងលក្ខខណ្ឌសម្រាប់ការផ្តល់សេវាដែលមានការពាក់ព័ន្ធ។

នៅកន្លែងផ្តល់សេវាសាធារណៈ ត្រូវរៀបចំឱ្យមានកន្លែងទទួលបណ្តឹងតវ៉ា ដែលអាចកើតមានឡើងជាយថាហេតុ ជាពិសេសក្នុងករណីមានការអនុវត្តខុសពីស្តង់ដារសេវា ឬ មានការយកកម្រៃលើសការកំណត់ ឬ ការផ្តល់សេវាសាធារណៈមានការយឺតយ៉ាវហួសរយៈពេលអតិបរមាដែលបានកំណត់ជាដើម។

ការទទួលបណ្តឹងតវ៉ារបស់អតិថិជន ត្រូវមានការបើកទូលាយដោយមានដាក់ប្រអប់សំបុត្រ លេខទូរស័ព្ទ សារអេឡិចត្រូនិក ដែលផ្តល់ឱកាសឱ្យអតិថិជនអាចធ្វើទំនាក់ទំនង ឬ ប្តឹងទៅខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ឬ អង្គភាពប្រឆាំងអំពើពុករលួយផងដែរ។

**ប្រការ៧ .–**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ទីតាំងជាក់លាក់ និងមានមន្ត្រីប្រចាំការដែលមានលក្ខណៈជាច្រកចេញចូលតែមួយ នៅទីតាំងដែលបានកំណត់ ដើម្បីទទួលបម្រើសេវាជូនអតិថិជនឱ្យបានទាន់ពេលវេលា តាមការកំណត់។ ទន្ទឹមនឹងនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ត្រូវពិនិត្យលទ្ធភាពប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាសាធារណៈឱ្យកាន់តែមានភាពងាយស្រួល មានតម្លាភាព និងមានប្រសិទ្ធភាព។

ដោយឡែកចំពោះការផ្តល់សេវាសាធារណៈរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវបន្តអនុវត្តតាមយន្តការ និងនីតិវិធីដែលមានស្រាប់រហូតដល់មានការប្រមូលផ្តុំឱ្យធ្វើឡើងតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ប្រការ៨ .–**

រាល់ការទទួលប្រាក់ចំណូលដោយផ្ទាល់ជាសាច់ប្រាក់ ឬ ជាមូលប្បទានប័ត្រ លើការប្រមូលចំណូលពីកម្រៃសេវាសាធារណៈ ត្រូវប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ដែលបើកផ្តល់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្របតាមប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់ និងសារាចរណែនាំលេខ ០០៥ សហវ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងបង្កាន់ដៃបង់ប្រាក់ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៩ .–**

រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវរៀបចំគម្រោងចំណូលថវិកាប្រចាំឆ្នាំដាច់ដោយឡែកពីគ្នា ដោយមានមូលដ្ឋានគ្រោងគិតចំណូលច្បាស់លាស់ និងគ្រោងចំណូលលម្អិតទៅតាមប្រភេទសេវាសាធារណៈនីមួយៗ យោងតាមសមត្ថកិច្ចប្រមូលចំណូលរៀងៗខ្លួន។

នៅពេលអនុវត្តចំណូល រដ្ឋបាលកណ្តាលក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវទទួលខុសត្រូវប្រាក់កាសលើប្រាក់ចំណូលដែលប្រមូលបាន បង់ប្រាក់ចំណូល និងធ្វើសលាកប័ត្រចំណូលថវិកាជាតិ ព្រមទាំងចុះកិច្ចបញ្ជិកាគណនេយ្យស្តីពីកិច្ចប្រតិបត្តិការចំណូល និងកត់ត្រាតាមដានប្រាក់ចំណូលនៅក្នុងជំពូក គណនី អនុគណនី នៃមាតិកាចំណូលថវិកា។

**ប្រការ១០ .–**

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការអនុវត្តចំណូលប្រចាំខែ និងប្រចាំឆ្នាំ ផ្ញើជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុរាជធានី ខេត្ត ឱ្យបានមុនថ្ងៃទី១០ នៃខែបន្ទាប់ សម្រាប់របាយការណ៍ប្រចាំខែ និងឱ្យបានមុនថ្ងៃទី១៥ ខែមករា នៃឆ្នាំបន្ទាប់ សម្រាប់របាយការណ៍ប្រចាំឆ្នាំ។

**ប្រការ១១ .-**

កម្រងសេវាសាធារណៈ ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃប្រកាសអន្តរក្រសួងនេះ អាចកែប្រែបានតាមការចាំបាច់ តាមរយៈប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ១២ .-**

ប្រកាសអន្តរក្រសួងនេះ មានអានុភាពជំនួស ប្រកាសរួមលេខ ៦៤៨ សហវ.ប្រក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៣ .-**

អគ្គលេខាធិការ នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្ត ប្រកាសអន្តរក្រសួងនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី.......... ខែ........... ឆ្នាំ២០១៩ តទៅ។

ថ្ងៃអង្គារ ៥រោច ខែ ផល្គុន ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជា សុផារ៉ា**

កន្លែងទទួល÷
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- អាជ្ញាធរសវនកម្មជាតិ
- អង្គភាពប្រឆាំងអំពើពុករលួយ
- សាលារាជធានី ខេត្ត
- ដូចប្រការ ១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ